គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

លេខ ៦០ ចេញផ្សាយថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២
No. 60 Released on November 18, 2022

និយ័តករបរធនបាលកិច្ច
Trust Regulator

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការទទួលខុសត្រូវចំពោះសកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល

## Responsibility for the Activities of the Physical Trustee of the Trust Company



https://cdn.vanderbilt.edu/vu-news/files/20190417225502/Building_trust_fi.jpg

យោងតាមច្បាប់ស្តីពី "បរធនបាលកិច្ច" (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតត្រូវត្រួតពិនិត្យយ៉ាងយកចិត្តទុកលើសកម្មភាពរបស់បរធនបាលរូបវន្តបុគ្គល ដែលបំពេញមុខងារក្នុងនាមក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវបង្កើត រក្សា និងតម្រូវឱ្យអនុវត្តនីតិវិធីជាលាយលក្ខណ៍អក្សរទាក់ទងនឹងការប្រព្រឹត្តនៃបរធនបាលរូបវន្តបុគ្គលរបស់ខ្លួន។

ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែលកើតចេញពីសកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលរបស់ខ្លួន ដែលទទួលបានការអនុញ្ញាតពីក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រោមលក្ខខណ្ឌនៃអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត។

សកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណ ដែលនាំឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតទទួលខុសត្រូវចំពោះបណ្តឹងរដ្ឋប្បវេណីរាប់បញ្ចូលទាំងការគេចវេះមិនចាត់វិធានការក្នុងស្ថានភាពជាក់ស្តែងណាមួយផងដែរ។

សកម្មភាពរបស់បរធនបាលរូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណ ដែលអនុញ្ញាតដោយក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬ ការអនុញ្ញាត ត្រូវគិតទាំងសកម្មភាពដែលទទួលបានការអនុញ្ញាត ដោយតុណ្ហីភាពដោយឈរលើមូលដ្ឋាន ដែលក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាត ដឹង ឬគួរតែដឹងថា បរធនបាលរូបវន្តបុគ្គលទទួលបានអាជ្ញាបណ្ណនោះ បានធ្វើសកម្មភាពនានា ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់ ឬបដិសេធ សកម្មភាពទាំងនោះ។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia www.trustregulator.gov.kh (855) 23 237 888
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

According to the Law on Trust (2019), relevant provisions and Prakas No. 003 dated January 26, 2022, on " Rules on the Management, Organization, and the Functioning of Trust ", the licensed or permitted trust companies must carefully monitor the activities of physical trustee who act on behalf of this trust company that received license or permission.

The licensed or permitted trust companies shall establish, maintain, and comply with the written procedures relating to the conduct of its physical trustee.

The licensed or permitted trust companies shall be subject to civil liability arising from the activities of the physical trustee who fulfill duty in the name of the trust company that was licensed or permitted.

The actions of a licensed physical trustee that lead a company to obtain a license and / or a liability for civil litigation, including evasion, do not act in certain circumstances.

The activities of the licensed physical trustee that lead the company to obtain the license and / or permit shall be considered based on the tacit permitted activities on the basis that the trust company that is licensed and / or authorized should know that the licensed physical trustee has taken any action and has not taken any prevention or deny such activity.

អត្ថបទ៖ កញ្ញា កេត ស្រីនិច | Article: KET Sreynich

ឯកសារយោង | References:
- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ (២០១៣)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.